**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន សាងវ៉ូ (ខេមបូឌា) ខូ អិលធីឌី**
**SANGWOO (CAMBODIA) CO., LTD**
លេខៈ...២១៩/៧.......ស.រ / ២០២០

SANGWOO

# កិច្ចព្រមព្រៀង
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារដោយបញ្ហាសេដ្ឋកិច្ច (គ្មានការបញ្ជាទិញ)

កិច្ចព្រមព្រៀងនេះត្រូវបានព្រមព្រៀងធ្វើឡើងរវាង **ក្រុមហ៊ុនសាងវ៉ូ (ខេមបូឌា) ខូ អិលធីឌី** និងថ្នាក់ដឹកនាំ **សហជីព ប្រតិភូបុគ្គលិកពេញសិទ្ធិ** នៃក្រុមហ៊ុនសាងវ៉ូ ដែលមានអាសយដ្ឋានស្ថិតនៅភូមិ **ផ្លូក** ឃុំ **ត្រពាំងគង** ស្រុក **សំរោងទង** ខេត្ត **កំពង់ស្ពឺ** ដោយបានព្រមព្រៀងទាំងស្រុងលើការព្យួរកិច្ចសន្យាការងារដោយមូលហេតុៈ **បញ្ហាសេដ្ឋកិច្ច (គ្មានការបញ្ជាទិញ)** ហើយភាគីទាំងពីរបានព្រមព្រៀងគ្នាទៅតាមលក្ខខ័ណ្ឌ និងដោយយោងទៅតាមមាត្រា ទី៧១ និងទី៧២ ច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

1. ព្រមព្រៀងព្យួរកិច្ចសន្យាការងារចំពោះបងប្អូន កម្មករ និយោជិតទាំងអស់ **ចំនួន ២៤៦២នាក់ រយៈពេល ៦០ថ្ងៃ** ដោយអនុវត្តចាប់ពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ ។
2. នៅក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ភាគីនិយោជកយល់ព្រមផ្តល់អោយនូវៈ
   a. ផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៣០ដុល្លារអាមេរិក** សម្រាប់កម្មករ និយោជិតម្នាក់ៗដែលព្យួរកិច្ចសន្យាការងារក្នុង១ខែ (យោងៈ សេចក្តីប្រកាសព័ត៌មាន ស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបន្ថែម សំដៅជួយដល់វិស័យឯកជន និងកម្មករ និយោជិតដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជម្ងឺកូវីដ-១៩ " ជុំទី៣, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២០ " និងសេចក្តីណែនាំលេខៈ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០)
   b. ចំពោះកម្មករ និយោជិត ដែលព្យួរកិច្ចសន្យាការងារក្រោម០៧ថ្ងៃ ក្រុមហ៊ុនយល់ព្រមផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៣០$** ដោយត្រូវគណនាផ្តល់ជូនជាសមាមាត្រទៅតាមថ្ងៃព្យួរកិច្ចសន្យាការងារជាក់ស្តែងនៅក្នុងខែនោះ
   c. ប្រាក់ឧបត្ថម្ភចំនួន **៣០ដុល្លារអាមេរិក** នឹងផ្តល់ជូនកម្មករ និយោជិតចំនួនពីរដងក្នុង១ខែតាមរយៈភ្នាក់ងារវីង និងធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA)
   d. ប្រាក់អត្ថប្រយោជន៍ផ្សេងៗ ត្រូវបានគណនាផ្តល់ជូនជាសមាមាត្រទៅតាមថ្ងៃធ្វើការជាក់ស្តែង នៃខែនីមួយៗ

ព្រះរាជាណាចក្រកម្ពុជា សាងវ៉ូ (ខេមបូឌា) SANGWOO (CAMBODIA) CO., LTD. ស្នាក់ការខេត្តកំពង់ស្ពឺ

3. ចំពោះនិយោជិតការិយាល័យ និងនិយោជិតបរទេសដែលព្យួរកិច្ចសន្យាការងារក៏ត្រូវទទួលបាន **៣០ ដុល្លាអាមេរិក** ដូចគ្នាផងដែរនៅកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ។

កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា និងផ្ដិតមេដៃនេះតទៅ ។

ថ្ងៃអង្គារ ០៩រោច ខែអាសាធ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅកំពង់ស្ពឺ ថ្ងៃទី.១៤....ខែ កក្កដា គ.ស ២០២០

**នាយកក្រុមហ៊ុន**

សាងវូ (ខេមបូឌា)
SANGWOO (CAMBODIA) CO., LTD.

Mr. **JISOO JANG**

**តំណាងកម្មករ និយោជិត និងសហជីព**

| | | | | |
|---|---|---|---|---|
| 4743 | 18063 | 663 | | |
| 641 | 4796 | 4948 | 1043 | 16786 |
| 164 | 19154 | 20194 | 16274 | 4889 |
| 30195 | | | | |